អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## ថវិកាស្នើសុំដោយ អ.វ.ត.ក សម្រាប់ដំណើការសវនាការ ឆ្នាំ២០១០ - ២០១១ ត្រូវបានបង្ហាញជូនប្រទេសផ្តល់ជំនួយ

សេចក្តីស្នើសុំថវិកាដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់ដំណើការសវនាការក្នុងឆ្នាំ ២០១០ និង២០១១ ត្រូវបានដាក់បង្ហាញជូនគណៈកម្មាការនៃអង្គការសហប្រជាជាតិគាំទ្រការកាត់ក្តីរបស់តុលាការខ្មែរក្រហម (UNAKRT) និង ក្រុមប្រទេសជាមិត្ត(GIS)របស់ (អ.វ.ត.ក) ក្នុងកំឡុងពេលកិច្ចប្រជុំមួយនៅក្នុងទីក្រុង New York នាសប្តាហ៍នេះ។ ការបង្ហាញនេះ ត្រូវបានដឹកនាំដោយ ឯកឧត្តម ក្រាញ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និង លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាលស្តីទី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

យោងតាមការប៉ាន់ស្មានលើចំនួនទឹកប្រាក់ ដែលតុលាការនេះត្រូវការ សម្រាប់ដំណើការសវនាការពីរឆ្នាំខាងមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំពុងស្នើសុំឲ្យមានការអនុម័តយល់ព្រមចំពោះថវិកាស្នើសុំ ដែលមានចំនួន ៤៦ លានដុល្លាសហរដ្ឋអាមេរិក សម្រាប់ឆ្នាំ២០១០ និង ៤៧ លាន ៣សែនទៀត សម្រាប់ឆ្នាំ ២០១១។ សមាសភាពខាងផ្នែកអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវការថវិកាសរុបចំនួន ៣៤លាន ៥សែន ដុល្លាសហរដ្ឋអាមេរិក សម្រាប់ឆ្នាំ២០១០ និង ៣៥លាន ៦សែន ដុល្លាទៀតសម្រាប់ឆ្នាំ២០១១ ដោយបូកបញ្ចូលថវិកាបម្រុង។ ចំណែកឯខាងភាគីកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ ត្រូវការថវិកាចំនួន ១១លាន ៥សែន ដុល្លាសហរដ្ឋអាមេរិកសម្រាប់ឆ្នាំ ២០១០ និង ១១លាន ៨សែន ដុល្លាទៀត សម្រាប់ឆ្នាំ ២០១១ ដោយបូកបញ្ចូលថវិកាបម្រុងផងដែរ។

ការចំណាយថវិកាប្រចាំឆ្នាំ អាចកើនឡើងដោយសារ អង្គបុរេជំនុំជម្រះមានសកម្មភាពកើនឡើង ដែលសកម្មភាពទាំងអស់តម្រូវឲ្យធ្វើការពេញម៉ោង និងម៉្យាងទៀត អង្គជំនុំជម្រះតុលាការកំពូលប្រហែលជានឹងចាប់មានដំណើការពេញម៉ោង ចាប់ពីពាក់កណ្តាលឆ្នាំ ២០១០ តទៅ។

ថវិកាដែលបានស្នើសុំនេះ ក៏បានគិតបញ្ចូលផងដែរនូវតម្លៃការពារក្តីសម្រាប់មេធាវីតំណាង ដែលទាក់ទងទៅនឹងសំនុំរឿងបន្ថែមផ្សេងៗទៀត។

ថវិកាសម្រាប់ឆ្នាំ២០១០ - ២០១១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងប្រកាសជាសាធារណៈ បន្ទាប់ពីបានការអនុម័តយល់ព្រមដោយ ក្រុមប្រទេសជាមិត្តរបស់ (អ.វ.ត.ក)។